# ដាំដំឡូងឈើ





គំរោងឥណទានកម្មវិធី ធនាគារ អភិវឌ្ឍន៍ អាស៊ី
(ADB) លេខ 1445-CAM ( SF )
នាយកដ្ឋាន ផ្សព្វផ្សាយកសិកម្ម
លេខ : ២ ឆ្នាំ ២០០៣

## ១-សារៈប្រយោជន៍របស់ដំឡូងឈើ :

ដំឡូងឈើជាដំណាំអាហារមួយប្រភេទ ដែលអាចហូបជំនួសបាយបាន នៅពេលអ្នកខ្វះអង្ករ ។ ក្រៅពីធ្វើជាអាហាររបស់ មនុស្ស គេអាចយកទៅធ្វើជាចំណីសត្វបានយ៉ាងល្អ ស្លឹកដំឡូងឈើ គេអាចយកទៅធ្វើជាបន្លែស្រស់ អន្លក់ ។ល ។ គេអាចយកម្សៅដំឡូងឈើធ្វើជា នំប៉័ងជំនួសស្រូវសាឡីបាន ជាងនេះទៅទៀត ដំឡូងឈើក៏ជាវត្ថុធាតុដើមរបស់រោងចក្រសំរាប់ផលិតក្រដាសធ្វើ ជ័រ ។

## ២-ប្រភេទពូជ :

ដំឡូងឈើដែលគេនិយមដាំនៅក្នុងប្រទេសកម្ពុជាយើងមានពូជនាំមកពីបរទេស និង ពូជនៅក្នុងស្រុក ពូជទាំងនោះមាន ពូជស្រាល និងពូជធ្ងន់ ។ បើគេបែងចែកពូជទៅតាមលក្ខណៈ មើមរបស់ដំឡូងក៏មានពីរប្រភេទដែរគឺ :

### *ក-ពូជដែលមនុស្សហូបមើម :*

ពូជនេះ មើមរបស់វាមានសាច់មើមម៉ដ្ឋរសជាតិផ្អែមច្រើនជាងល្វីងហើយវាជាពូជដែលធន់ទ្រាំទៅនឹងការរាំងស្ងួត និង មានរយៈពេលលូតលាស់ខ្លី គឺ ៨-១២ ខែ ។

## ២-ប្រភេទពូជសំរាប់ធ្វើម្សៅនិងចំណីសត្វ :

ពូជនេះ មើមរបស់វាមានសាច់មើមគ្រើមមិនស្វិតមានរសជាតិល្វីងទាំងអស់ ។ ប្រភេទពូជនេះមានរយៈពេលលូតលាស់វែង ។

# ៣_បច្ចេកទេសដាំដុះ :

## ៣.១-ការធ្វើដី :

_ អ្នកត្រូវកាប់ឬភ្ជួរដីអោយបានជំរៅប្រហែលពី *២០_៣០ស.ម* ភ្ជួរឱ្យបានពីរទៅបីដងដើម្បីឱ្យដីផុសល្អ បន្ទាប់មកអ្នកត្រូវរើសយកស្មៅចេញអោយបានស្អាត ។

_ អ្នកត្រូវហាលដីអោយបានស្ងួតល្អ ។



*ការរៀបចំហាលដី*

### ៣.២-ការរើសពូជ :

- អ្នកត្រូវរើសយកដើមដំឡូងណា ដែលធំមានលក្ខណៈដុះលូតលាស់ល្អ និង មានអាយុកាលយ៉ាងតិចមួយឆ្នាំ ។

- អ្នកត្រូវកាត់ជាកង់ៗ *ប្រវែងពី ១៥-២០ស.ម* ។

### ៣.៣-រដូវកាលដាំដុះ :

អ្នកគួរដាំដំឡូង នៅពេលដែលដីមានសំណើមគ្រប់គ្រាន់ ហើយសំណើមនៅក្នុងដីនោះអាចធានានូវការលូតលាស់របស់ដំឡូង ក្នុងរយៈពេល៤-៥ខែ ដូច្នេះពេលវេលាដ៏សមស្រប និងល្អបំផុតនោះ គឺក្នុងអំឡុងខែវិច្ឆិកា និងធ្នូ ជាពិសេសបន្ទាប់ពីទឹកទន្លេស្រកចុះ ។

### ៣.៤-វិធីសាស្រ្តដាំដុះ :

*ការដាំដំឡូងឈើជាទូទៅគេដាំតាមបីរបៀបៈ*

#### ក-ការដាំបញ្ឈៀង :

ការដាំតាមវិធីនេះ អ្នកត្រូវដាក់កំណាត់ដំឡូងឈើរាងបញ្ឈៀងដែលមានមុំពី ២០-៤៥ ដឺក្រេ ដោយប្រៀបធៀបទៅនឹងដី ។ ជាទូទៅការដាំអ្នកត្រូវកប់ដើមដំឡូងឈើផ្នែកខាងក្រោមនៃដងដើម ទៅក្នុងដីអោយជ្រៅ ជួនកាលអ្នកអាចកប់ដីជិតតែម្តង ឬ ទុកផ្នែក ខាងចុងដើមលេចផុតពីដីបន្តិច ។